# ទឹកជ្រោះតែមួយ

The Only One Waterfall

Written by Manith

ពណ៌ស...

ពណ៌សមួយនេះ ខ្ញុំតែងតែឃើញរាល់ព្រឹក និងសម្លឹងមើលវាយ៉ាងណាក៏មួយម៉ោងជារៀងរាល់ព្រឹកមុននឹងងើបពីគ្រែដំណេក។ ពន្លឺថ្ងៃដែលជះចូលមកតាមបង្អួចហាក់ធ្វើឲ្យខ្ញុំកក់ក្ដៅឡើង តែរាងកាយរបស់ខ្ញុំហាក់មិនចង់កម្រើកសោះ។

ពណ៌សនោះគឺជាជញ្ជាំងពិដាននៃបន្ទប់ដេករបស់ខ្ញុំ។ ព្រឹកនេះ ខ្ញុំនៅដេកសណ្ដូកលើគ្រែមើលទៅពិដានដូចសព្វមួយដង។ ខ្ញុំធ្លាប់ជាមនុស្សស្វាហាប់ ឈ្លាសវៃ និងរហ័សរហួនណាស់ តែការដេកស្ងៀម រស់ស្ងាត់ និងដេកស្ងប់មើលពិដាន វាបានក្លាយជាទម្លាប់ថ្មីរបស់ខ្ញុំទៅហើយ។ កុំថាឡើយប្រែប្រួលតែខ្ញុំ សូម្បីតែពិភពលោកពេលនេះក៏ប្រែប្រួលដែរ។

ជំងឺកូវីដ១៩ បានរាតត្បាតអស់មួយឆ្នាំជាងទៅហើយ ឯថ្ងៃនេះគឺថ្ងៃដំបូងនៃការបិទខ្ទប់រយៈពេលពីរសប្ដាហ៍ សូមបញ្ជាក់ម្ដងទៀត...

បិទខ្ទប់រយៈពេលពីរសប្ដាហ៍!

ខ្ញុំមិនបានត្រៀមខ្លួននោះទេ មិនថាជាជំងឺរាតត្បាត ឬសូម្បីតែការបិទខ្ទប់។ គ្រប់យ៉ាងនៅជុំវិញខ្លួនខ្ញុំបានប្រែប្រួល ហើយវាបានបង្ខំឲ្យខ្ញុំប្រែប្រួល ទាំងដែលខ្ញុំជាមនុស្សដែលស្អប់ការប្រែប្រួល។ ទីបំផុត ខ្ញុំគ្មានជម្រើសអ្វីក្រៅពីត្រូវតែប្រែប្រួលតាមពិភពលោកដ៏ស្មុគស្មាញមួយនេះ។

ខ្ញុំឈ្មោះ គង្គា អាយុ ២២ឆ្នាំ ជាអ្នកនិពន្ធសៀវភៅលើកទឹកចិត្ត ដែលបានទទួលស្គាល់ស្នាដៃពីអ្នកអាន និងស្ថាប័ននានា។ ពិតជាគួរឲ្យអស់សំណើចណាស់ ខ្ញុំអាចលើកទឹកចិត្តមនុស្សរាប់លាននាក់បាន តែពេលនេះខ្ញុំបែរជាមិនអាចរកអ្វីមកលើកទឹកចិត្តឲ្យខ្លួនឯងបានសោះ។

តាំងពីជំងឺនេះបង្ហាញខ្លួនមក ជីវិតខ្ញុំបានប្រែប្រួលសឹងតែមិនដឹងខ្លួន។ កម្មវិធីជាច្រើនត្រូវបានផ្អាក សៀវភៅថ្មីត្រូវផ្អាកចេញផ្សាយ សៀវភៅដទៃទៀតក៏សរសេរមិនចេញ ឯចំណូលក៏អន់ថយទៅតាមនោះ។ ពេលខ្លះខ្ញុំយល់ថា គ្រប់យ៉ាងរាំងស្ទះតឹងថប់ ដូចប៉េងប៉ោងសប់ខ្យល់យ៉ាងណាក៏មិនបែក វាចេះតែធំទៅៗតឹងទៅៗ។ ពេលដែលដឹងដំណឹងបិទខ្ទប់ភ្លាម ខ្ញុំបានត្រៀមស្បៀងមួយចំនួន និងរៀបចំផែនការណ៍ប្រចាំថ្ងៃគឺ ត្រូវអានសៀវភៅ ហាត់ប្រាណ សម្រាកខួរក្បាល តែដល់ពេលមែនទែនទៅស្ទើក៏មិនធ្វើដែរ ពោលគឺយើងបែរជាកើតមានអារម្មណ៍អស់សង្ឃឹម តប់ប្រមល់ ថែមទាំងពេលខ្លះមិនចង់កម្រើកដៃកម្រើកជើងទៀតផង។ ស្ថានភាពពិភពលោកក្នុងពេលនេះបានធ្វើឲ្យយើងមានសម្ពាធផ្លូវចិត្តជាខ្លាំង។

មនុស្សដែលធ្លាប់តែដើរហើរសេរីគ្រប់ទីកន្លែង បែរជាត្រូវមកដេកស្ងៀមមួយកន្លែង។ ទោះចេញទៅខាងក្រៅបាន ក៏ត្រូវពាក់ម៉ាស់ លាងសម្អាតដៃជាមួយសាប៊ូ និង អាល់កុលជាញឹកញាប់ រហូតដល់ដៃរបស់ខ្ញុំឡើងគ្រើម និងមានរបកស្បែកខ្លះៗ ដោយសារតែសម្អាតដៃញឹកញាប់ពេក។ មនុស្សដែលចូលចិត្តញ៉ាំអាហារឆ្ងាញ់ៗ បែរជាមកត្រូវកំណត់របបអាហារនិងមិនអាចស្វែងរកអាហារដែលខ្លួនចូលចិត្តបាន។ មានខោអាវស្អាតពាក់ តែមិនដឹងពាក់ទៅណា មានគំនិតចង់ធ្វើអ្វីមួយ តែមិនអាចធ្វើសកម្មភាពអ្វីបាន។ នៅមានរឿងច្រើនទៀតណាស់ ទាំងនេះត្រឹមតែជាកត្តាតូចៗ ដែលធ្វើឲ្យយើងពិបាកក្នុងការសម្របខ្លួនប៉ុណ្ណោះ ព្រោះភាពជឿនលឿន វាបានជួយឲ្យយើងមានភាពងាយស្រួលក្នុងការធ្វើអ្វីគ្រប់យ៉ាង ដល់ពេលដែលយើងបាត់បង់វាភ្លាម យើងស្រាប់តែយល់ថា យើងបាត់បង់សេរីភាពនៃភាពជឿនលឿននោះដូចគ្នា។

ពិភពលោកជួបប្រទះបញ្ហាធំយ៉ាងនេះ ទោះគ្មានរឿងអ្វី ក៏សប្បាយចិត្តមិនចេញដែរ។ ទីដែលធ្លាប់មានមនុស្សកុះករ ប្រែជាស្ងប់ស្ងាត់ ការប្រាស្រ័យទាក់ទងប្រចាំថ្ងៃគឺពិបាកជាងមុនឆ្ងាយណាស់ ឯព័ត៌មានជុំវិញពិភពលោកទាក់ទងនឹងជំងឺកូវីដ១៩ វារឹតតែបានធ្វើឲ្យយើងភ័យព្រួយបារម្ភមិនលស់មួយនាទីណា។

នេះហើយជាហេតុផលដែលខ្ញុំដេកមើលពិដានរាល់ព្រឹក ព្រោះ...

ខ្ញុំបាត់បង់ខ្លួនឯង...

ខ្ញុំបាត់បង់គោលដៅក្នុងជីវិត ព្រោះរយៈពេលបិទខ្ទប់នេះ គឺរស់មួយថ្ងៃដើម្បីតែមួយថ្ងៃប៉ុណ្ណោះ គ្មានអ្វីក្រៅពីញ៉ាំ និងដេកមើលពិដានទេ។ ជាពិសេសបើអ្នកមានគ្រួសារដែលរីករាយកក់ក្ដៅ អ្នកប្រហែលជាមិនស្មុគស្មាញក្នុងចិត្តដូចខ្ញុំនោះទេ។ រឿងដែលពិបាកបំផុតក្នុងរយៈពេលបិទខ្ទប់នេះ គឺខ្ញុំត្រូវប្រឈមមុខជាមួយប៉ា និងប្អូនប្រុសរបស់ខ្ញុំ។

ខ្ញុំជាកូនច្បងក្នុងគ្រួសារ និងជាកូនស្រីតែម្នាក់។ គ្រួសារពួកយើងមានគ្នាបួននាក់ គឺ ម៉ាក់ ប៉ា ខ្ញុំ និងប្អូនប្រុសរបស់ខ្ញុំ អាយុប្រហែល១៦ឆ្នាំ។ ទំនាក់ទំនងពួកយើងមិនសូវជាល្អប៉ុន្មាននោះទេ តាំងពីម៉ាក់បានស្លាប់ និងបន្ទាប់ពីប៉ា... ណ្ហើយ ប៉ាមិនបានស្លាប់ទៅតាមម៉ាក់នោះទេ គ្រាន់តែពួកយើងបីនាក់មានរឿងមិនចុះសម្រុងជាមួយគ្នាប៉ុណ្ណោះ។

មួយជីវិតខ្ញុំនេះ អ្វីក៏ខ្ញុំមិនដែលគេចវេះដែរ តែអ្វីដែលខ្ញុំគេចវេះមានតែមួយគត់គឺ...

អាហារពេលល្ងាចជុំគ្រួសារ!

គ្រាន់តែនិយាយពាក្យនេះក៏ស្ដាប់ទៅឆ្គាំឆ្គងដែរ ហើយមើលពេលនេះចុះ បើប្រទេសប្រកាសអាសន្នបិទខ្ទប់មិនឲ្យប្រជាពលរដ្ឋចាកចេញពីផ្ទះបែបនេះ តើឲ្យខ្ញុំគេចវេះពីវាយ៉ាងណាទៅ?

ខ្ញុំក្រឡេកមើលនាឡិកាព្យួរជញ្ជាំង រួចក៏បានឃើញទ្រនិចនាឡិកាចង្អុលទៅម៉ោង១២ថ្ងៃត្រង់។ បានហើយ មើលពិដានគ្រប់មួយម៉ោងហើយ ហើយក៏ដល់ពេលបាយថ្ងៃល្មមដែរ។ បាយព្រឹកនិងបាយថ្ងៃដាក់ចូលគ្នាតែម្ដងទៅ។ ខ្ញុំក៏សម្រេចចិត្តងើបពីគ្រែដំណេក ហើយឈានជើងដើរយ៉ាងពិបាក ដោយសារតែបន្ទប់ខ្ញុំនេះគឺពោរពេញដោយអីវ៉ាន់រាយប៉ាយឥតសណ្ដាប់ធ្នាប់ខ្លាំងជាទីបំផុត។

តុបាយដ៏ស្ងប់ស្ងាត់។ មិនមែនតុទេដែលស្ងប់ស្ងាត់ តែមនុស្សទៅវិញទេដែលស្ងាត់មិននិយាយអ្វី។ ប្អូនប្រុសរបស់ខ្ញុំលើកវ៉ែនតាឡើងលើបន្តិច ព្រមទាំងលួចមើលខ្ញុំជារឿយៗកាត់តាមកញ្ចក់វ៉ែនតាក្រាស់ឃ្មឹក។ វាមានឈ្មោះថា គិរី។

ប៉ុកៗ!

សំឡេងស្បែកជើងកែងទង្គិចនឹងផ្ទៃឥដ្ឋក្នុងផ្ទះបានបន្លឺឡើង។ ស្ត្រីចំណាស់ក្នុងឈុតរ៉ូបពណ៌ក្រហម រួមជាមួយស្បែកជើងកែងចោទ បានបង្ហាញវត្តមានឡើងនៅតុបាយជាមួយចានម្ហូបអាហារជាច្រើនក្នុងដៃផង។ ផ្ទៃមុខរបស់គាត់ពោរពេញដោយម្សៅក្រាស់ៗ និងបបូរមាត់ក្រហម ដែលធ្វើឲ្យខ្ញុំយល់ថា ការតុបតែងខ្លួនបែបនេះពិតជាមិនស័ក្តិសមនឹងគាត់អីបន្តិចសោះ។

គាត់គឺជាប៉ារបស់ខ្ញុំ!

អ្នកស្តាប់មិនច្រឡំទេ ស្ត្រីក្នុងឈុតក្រហម និងស្បែកជើងកែងចោទនេះហើយជាឪពុកបង្កើតរបស់ខ្ញុំ។ បន្ទាប់ពីលាងសាប៊ូសម្អាតដៃរួចរាល់ ពួកយើងក៏ដាក់ខ្លួនអង្គុយជុំគ្នានៅតុបាយ។

"ម្ហូបឆ្អិនហើយ ឆាប់ញ៉ាំទៅកូន" សំឡេងរបស់គាត់ បានបង្ហាញយ៉ាងច្បាស់ថា គាត់ពិតជាសប្បាយចិត្តណាស់ដែលបានបាយជុំកូនៗថ្ងៃនេះ តែគ្មានសំឡេងរីករាយណាមួយឆ្លើយតបទៅគាត់វិញសោះ។ ខ្ញុំសម្លឹងមើលម្ហូបផ្អឹង ហើយក៏មិនបានសម្លឹងមើលមុខគាត់ដែរ ប៉ុន្តែខ្ញុំដឹងច្បាស់ណាស់ថា គាត់កំពុងតាមមើលទឹកមុខរបស់ខ្ញុំមិនដាក់ភ្នែក។ គិរីជ្រំបាយមិនមាត់មិនក ឯប៉ាបានត្រឹមតែតាមមើលមុខកូនៗដោយតឹងតែង។ គាត់បន្ទូរដង្ហើមមួយយ៉ាងធំ រួចព្យាយាមញញឹមនិយាយម្តងទៀត។

"ញ៉ាំបាយទៅកូន!" និយាយរួច ប៉ាក៏ដួសម្ហូបខ្លះដាក់ចានខ្ញុំ និងចានគិរី។ គិរីហាក់ក្រែងចិត្តប៉ា វាក៏ញញឹមរួចញ៉ាំមួយម៉ាត់ទាំងបង្ខំ ហាក់បីដូចជាឃើញមុខខ្ញុំនៅតុបាយនេះ ធ្វើឲ្យប្រព័ន្ធរំលាយអាហាររបស់វាមានបញ្ហាយ៉ាងអ៊ីចឹង។ តាំងពីដើមពីគេង មិនទាន់មានអ្វីចូលពោះសោះ ទើបខ្ញុំសម្រេចចិត្តកៀរពងទាចៀនដែលប៉ាដួសឲ្យទៅម្ខាង រួចតម្រង់ទៅរកសម្លក្តៅៗ។ គ្រានោះ ប៉ានិងខ្ញុំក៏លូកដៃដួសម្ហូបដំណាលគ្នា បណ្តាលឲ្យស្លាបព្រាយើងទាំងពីរទង្គិចគ្នា។ ខ្ញុំមើលមុខគាត់ គាត់មើលមុខខ្ញុំហាក់មិនព្រមដកថយរៀងខ្លួន។ ខ្ញុំក៏សុខចិត្តដកថយចុះ រួចក៏ដួសបាយសដាក់មាត់វិញ។

ហេតុអ្វីបាយមួយពេលនេះពិបាកលេបម្ល៉េះ?

បន្ទាប់ពីដាក់បាយបានមួយម៉ាត់ ខ្ញុំក៏ដាក់ស្លាបព្រាសមចុះ រួចក្រោកឡើងដើរទៅបន្ទប់ ដោយមិនភ្លេចនិយាយមួយម៉ាត់ចុងក្រោយ។

"ខ្ញុំឆ្អែតហើយ"

គ្រាន់តែឮប៉ុននេះភ្លាម ប៉ាស្រាប់តែស្ទុះដើរមកតាមខ្ញុំដល់បន្ទប់ដោយបន្លឺសូរជើងខ្លាំងៗ។

"គ្រាន់តែបាយជាមួយយើងមួយចាន វាពិបាកណាស់មែនទេគង្គា?"

ឮសម្ដីខ្លាំងៗរបស់គាត់បែបនេះហើយ ខ្ញុំក៏បែរមុខទៅសម្លឹងគាត់វិញដោយខ្សែភ្នែកត្រជាក់ល្ហឹម។

"បាយមិនពិបាកទេ តែអារម្មណ៍វាពិបាក" ខ្ញុំតបដោយសំឡេងស្មើៗ។ មុខដែលលាបម្សៅក្រាស់ៗរបស់ប៉ា កំពុងបង្ហាញពីអារម្មណ៍ខឹងសម្បារ សឹងតែធ្វើឲ្យម្សៅកកលើមុខគាត់ ប្រេះដូចដីរាំងស្ងួតបែកក្រហែងទៅហើយ។

"ប្រហែលជាពិបាកខ្លាំងហើយ ទើបបានជាឯងគេចមុខពីឪពុកបានច្រើនឆ្នាំយ៉ាងនេះ... មើល៍! ប្រាប់យើងមកមើល៍ យើងធ្វើឲ្យអារម្មណ៍ឯងពិបាកស្អីខ្លះ? លុយយើងមិនដែលសុំឯងចាយទេ យើងឈឺក៏មិនដែលទៅសុំឲ្យឯងមកមើលដែរ យើងមិនដឹងថាយើងបានធ្វើខុសអ្វីទេ"

ឮប៉ានិយាយបែបនេះហើយ វាធ្វើឲ្យខ្ញុំអស់សំណើចបន្តិច។ មែនហើយ ប៉ាមិនទាំងដឹងថាគាត់បានធ្វើអ្វីលើខ្ញុំផង តើឲ្យគាត់យល់ពីទំនាក់ទំនងយើងទាំងពីរនាក់ឪពុកកូនយ៉ាងម៉េចទៅ?

"ប៉ាក៏មិនដែលចង់មកមើលថែខ្ញុំដែរ មួយជីវិតខ្ញុំនេះ គឺខ្ញុំមើលខ្លួនឯង ប៉ានិងម៉ាក់លែងលះតាំងពីខ្ញុំនៅតូច ម៉ាក់យកខ្ញុំទៅនៅជាមួយ ពេលនោះខ្ញុំក៏មើលថែខ្លួនឯង បន្ទាប់ពីម៉ាក់ស្លាប់ ខ្ញុំក៏មើលថែខ្លួនឯង... ហើយផ្ទះដែលប៉ាកំពុងឈរនេះ គឺខ្ញុំទិញដោយខ្លួនឯង... អ្វីដែលប៉ាធ្វើឲ្យខ្ញុំគឺមានតែមួយប៉ុណ្ណោះ..."

ខ្ញុំទច់សម្ដីត្រឹមនេះ ហើយប៉ាក៏ស្ងាត់មាត់រង់ចាំស្ដាប់ខ្ញុំនិយាយបន្តដោយចិត្តអន្ទះសា។ ទឹកភ្នែកជាច្រើនដំណក់បានដក់នៅក្នុងរង្វង់ភ្នែកយើងទាំងពីរ ព្រោះពេលដែលជួបគ្នារាល់ដង យើងទាំងពីរមិនបានធ្វើអ្វីក្រៅតែពីនិយាយពាក្យគ្រោតគ្រាតឲ្យគ្នាទៅវិញទៅមកនោះទេ។ គិរីប្អូនខ្ញុំ វាក៏ដើរចូលមកឈរក្រោយខ្នងប៉ាជាមួយទឹកភ្នែករលីងរលោង ដ្បិតវាប្រហែលជាឈឺចិត្តណាស់ហើយ ដែលខ្ញុំនិងប៉ាតែងតែស្រែកដាក់គ្នា ច្រើនជាងនិយាយគ្នាធម្មតា ហើយនេះក៏ប្រហែលជាលើកទីមួយដែរ

ដែលខ្ញុំលែងគេចវេះ ហើយព្រមនិយាយរឿងដែលគាំងស្ទះក្នុងចិត្តទាំងប៉ុន្មានប្រាប់ទៅប៉ា។ ខ្ញុំក៏និយាយបន្ត...

"អ្វីដែលប៉ាធ្វើឲ្យខ្ញុំ គឺត្រឹមតែជាការសន្យាឲ្យតែរួចពីមាត់ប៉ុណ្ណោះ"

"សន្យាអី?"

សំណួរដ៏ក្ដុកក្ដួលពីប៉ា បានធ្វើឲ្យទឹកភ្នែកមួយតំណក់ហូរចុះមកកាត់ថ្ពាល់ខ្ញុំ។ ខ្ញុំទ្រាំលែងបានមែនទែនហើយ ទើបខ្ញុំប្រញាប់រុញគាត់ចេញពីបន្ទប់ រួចបិទទ្វារចាក់សោសំងំយំតែម្នាក់ឯង។ បែបនេះហើយទើបខ្ញុំគេចមិនចង់ជួបមុខប៉ា ព្រោះគ្រប់យ៉ាងគឺគាត់មិនយល់ គាត់មិនចាំ ព្រោះអ្វីដែលគាត់យល់និងចាំ មានតែខ្លួនគាត់ម្នាក់ប៉ុណ្ណោះ។ ខ្ញុំមិនចង់ប្រឈមមុខនឹងរឿងនេះទេ ខ្ញុំពិតជាស្អប់អារម្មណ៍នេះណាស់។

បាយជុំគ្នាលើកដំបូងប្រយុទ្ធគ្នាសឹងបែកផ្ទះទៅហើយ ទម្រាំបាយមួយថ្ងៃបីដងទៀត ផ្ទះនេះនឹងត្រូវធរណីស្រូបជាមិនខាន។

បើបានជាមិនអាចចាកចេញពីផ្ទះ ហើយក៏មិនអាចបាយឲ្យស្រួលចិត្តដែរនោះ ខ្ញុំក៏សម្រេចចិត្តថា ក្នុងរយៈពេលបិទខ្ទប់នេះ ខ្ញុំនឹងធ្វើអ្វីមួយដែលខ្ញុំរកពេលធ្វើសឹងមិនបាន នោះគឺ រៀបបន្ទប់។

ខ្ញុំចាប់ផ្ដើមរៀបពីមួយកន្លែងទៅមួយកន្លែង រហូតដល់បន្ទប់ដ៏រញ៉េរញ៉ៃប្រែជាស្អាតឡើងបន្តិចម្ដងៗ។ ខ្ញុំបានរំកិលទូខោអាវទៅផ្នែកម្ខាងទៀតនៃបន្ទប់ ដើម្បីឲ្យបន្ទប់មើលទៅទូលាយឡើងបន្តិច។ គ្រានោះ ខ្ញុំបានប្រទះឃើញក្រដាសគំនូរកញ្ចាស់មួយ ដែលខ្ញុំគូរកាលពីនៅក្មេងៗ ហើយដាក់ជាប់ខ្លួនមករហូត។ ខ្ញុំបានយកវាទៅព្យួរជាប់ជញ្ជាំង ហើយយកទូធំនេះមកបាំង រហូតសឹងតែភ្លេចថា រូបនេះនៅក្បែរខ្លួនខ្ញុំមករហូត។ ខ្ញុំលូកដៃទៅយកក្រដាសនោះមកមើល ដោយចិត្តក្ដុកក្ដួល។

វាគឺជាគំនូរដ៏ក្រវេមក្រវាម ដែលខ្ញុំបានគូរជាមួយនឹងប្អូនប្រុសកាលពីនៅក្មេង ដែលនិយាយពីគ្រួសារយើងទាំងបួននាក់ទៅលេងទឹកជ្រោះប៊ូស្រា។ ក្នុងគំនូរនោះ យើងបានឃើញទឹកជ្រោះធ្លាក់ពីលើទីខ្ពស់ អមដោយរុក្ខាខៀវខ្ចីគ្រប់ប្រភេទ ហើយនិងឃើញមានម៉ាក់ ប៉ា គិរី និងខ្ញុំ កំពុងឈរលើកដៃសម្លឹងទៅទឹកជ្រោះយ៉ាងសប្បាយរីករាយ។

នរណាទៅដឹងថា ជីវិតពិត និងជីវិតក្នុងរូបគំនូរ ខុសគ្នាខ្លាំងយ៉ាងនេះនោះ។

ថ្ងៃនោះថ្ងៃដែលប៉ាបានសន្យាថានឹងនាំខ្ញុំនិងគិរីទៅលេងទឹកជ្រោះប៊ូស្រា ខ្ញុំចាំគ្រប់ពាក្យសម្ដី គ្រប់កាយវិការរបស់គាត់។ កាលណោះ ខ្ញុំទើបតែមានអាយុ១០ឆ្នាំ ប៉ាប្រាប់ខ្ញុំនិងគិរីថា ថ្ងៃស្អែកគាត់នឹងនាំពួកខ្ញុំទៅទឹកជ្រោះប៊ូស្រា។ គាត់ពិតជាស្រលាញ់សម្បត្តិធម្មជាតិនោះណាស់ នេះហើយជាហេតុដែលគាត់ដាក់ឈ្មោះខ្ញុំថា គង្គា និងដាក់ឈ្មោះប្អូនប្រុសខ្ញុំថា គិរី។ គង្គាមានន័យថា ទឹក គិរីមានន័យថា ភ្នំ។ គាត់ចង់ដាក់ឈ្មោះកូនរបស់គាត់ទាំងពីរ តាមអ្វីដែលគាត់ស្រលាញ់បំផុត។

ស្អែកឡើង ខ្ញុំ និងគិរីបានស្លៀកពាក់ស្រេចបាច់ រួចក៏ដើរចេញពីបន្ទប់ បំណងទៅរកប៉ា និងម៉ាក់។ សំឡេងឈ្លោះប្រកែកគ្នាបានឮឡើងយ៉ាងច្បាស់។ ខ្ញុំនិងគិរីរលីងរលោងឡើង ព្រោះពួកខ្ញុំបានស្ដាប់ឮប៉ានិយាយប្រាប់ម៉ាក់ថា...

គាត់ចង់ក្លាយជាមនុស្សស្រី!

ម៉ាក់មិនបានតបអ្វីច្រើនឡើយ គាត់ដើរចេញមក រួចអូសដៃខ្ញុំចេញពីគិរី ហើយគ្រប់យ៉ាងក៏បានប្រែប្រួលចាប់ពីថ្ងៃនោះ។ ប៉ា និងម៉ាក់បានលែងលះគ្នា។ ម៉ាក់យកខ្ញុំទៅនៅជាមួយ ឯគិរីត្រូវរស់នៅជាមួយប៉ា។ យូរៗម្ដងទើបពួកយើងបានជួបគ្នា។ ខ្ញុំមិនចង់រស់នៅបែកគ្នាបែបនេះឡើយ ខ្ញុំនឹកប្អូន ខ្ញុំនឹកប៉ា ខ្ញុំនឹកសំឡេងសើចក្អាកក្អាយនៅតុបាយរាល់ល្ងាច។

ប្រមាណពីរឆ្នាំក្រោយមក ប៉ាក៏បានសន្យាថានឹងនាំខ្ញុំនិងគិរីទៅលេងទឹកជ្រោះប៊ូស្រាម្ដងទៀត។ ម៉ាក់ក៏បានអនុញ្ញាត ហើយខ្ញុំចាំបានថា ថ្ងៃនោះជាថ្ងៃដែលខ្ញុំសប្បាយចិត្តបំផុតក្នុងជីវិត។ ខ្ញុំស្លៀកពាក់រួចរាល់ ហើយចុះមកចាំប៉ានៅខាងក្រោម តែមិនបានឃើញវត្តមានប៉ាឡើយ បន្ទាប់ពីចាំអស់ជាច្រើនម៉ោង។ មួយសន្ទុះធំ ម៉ាក់ក៏បានដើរមកនាំខ្ញុំឡើងទៅលើផ្ទះវិញ រួចប្រាប់ខ្ញុំថា ប៉ាឈឺធ្ងន់ និងត្រូវបាននាំខ្លួនចូលសម្រាកក្នុងមន្ទីរពេទ្យ។ ប៉ុន្មានថ្ងៃក្រោយមក ទើបខ្ញុំបានដឹងថា ប៉ាមិនបានធ្លាក់ខ្លួនឈឺទេ គឺគាត់បានជ្រើសយកថ្ងៃនោះទៅវះកាត់ប្ដូរភេទ ព្រមទាំងភ្លេចឈឹងមិននឹកនាថាគាត់បានសន្យានឹងខ្ញុំថា នឹងនាំខ្ញុំទៅលេងទឹកជ្រោះប៊ូស្រាឡើយ។ សន្យាឪពុក គឺជាសន្យាដ៏មានតម្លៃខ្លាំងបំផុតរបស់កូន។ សម្ពន្ធភាពដែលកំពុងប្រេះស្រាំ

ស្រាប់ទៅហើយនោះ បែរជាត្រូវប្រេះបែកខ្ទាត់ខ្ទាយ ដោយសារតែសន្យាប្រយោល មួយនោះថែមទៀត។

តាំងពីថ្ងៃនោះមក ខ្ញុំបានប្រាប់ខ្លួនឯងថា គ្រប់យ៉ាងលែងដូចមុនហើយ ព្រមទាំងដាស់តឿនខ្លួនឯង កុំឲ្យលិចលង់ក្នុងសុភមង្គលដែលមិនមែនជាការពិត។

ពាក្យសន្យាដែលគ្មានថ្ងៃក្លាយជាការពិត...

បើប៉ាមានក្ដីស្រមៃរបស់គាត់ ខ្ញុំក៏ត្រូវមានក្ដីស្រមៃជារបស់ខ្ញុំខ្លួនឯងដែរ។

បើគាត់មិនចងចាំខ្ញុំ ខ្ញុំក៏មិនចាំបាច់ចងចាំគាត់ដែរ។

ប៉ុន្មានឆ្នាំក្រោយមក ម៉ាក់បានស្លាប់ដោយរោគាពាធ។ ខ្ញុំធំពេញវ័យគ្រប់គ្រាន់ និងមានរបរជាក់លាក់មួយ ទើបខ្ញុំរស់នៅម្នាក់ឯងជាមនុស្សស្រីឯករាជ្យ ដោយមិនគិតនឹងរំខានប៉ាឡើយ។ មិនត្រឹមតែសម្ពន្ធភាពប៉ានិងខ្ញុំត្រូវឃ្លាតឆ្ងាយទេ ខ្ញុំនិងប្អូនប្រុសក៏ដូចគ្នា។

ថ្ងៃមួយខ្ញុំបានតាំងចិត្តទៅលេងទឹកជ្រោះប៊ូស្រាជាលើកដំបូង។ ខ្ញុំទៅតែម្នាក់ឯងប៉ុណ្ណោះ ហើយពិតជាបានទៅដល់ទឹកជ្រោះប៊ូស្រាដូចបំណងមែន។ ខ្ញុំត្រូវចំណាយពេលប្រហែល៧ម៉ោងទម្រាំទៅដល់រមណីយដ្ឋាននោះ។

ពិតណាស់ ទឹកជ្រោះនោះពិតជាស្អាតមែន។ សម្បត្តិធម្មជាតិមួយនេះ ពិតជាពិសេសដូចឈ្មោះដែលប៉ាដាក់ឲ្យខ្ញុំនិងប្អូនប្រុសមែន។ ខ្ញុំបានឈរសម្លឹងមើលទៅទឹកដែលធ្លាក់ខ្លាំងមិនប្រណី ឯកម្ទេចល្អិតល្អងនៃទឹក បានខ្ទាតសាចមកប៉ះសាច់ក្ដៅៗរបស់ខ្ញុំ ជួយឲ្យស្បែកដែលក្ដៅស្ងួត មានសំណើមឡើងបន្តិច តែវាពិតជាមិនបានជួយឲ្យកម្ដៅក្នុងចិត្តថមថយខ្លះសោះ។

តើមានន័យអ្វីទៅ? បើមកដល់ទីនេះតែម្នាក់ឯងនោះ...

គ្មានគ្រួសារ គ្មានប៉ា គ្មានម៉ាក់...

គ្រប់យ៉ាងហាក់ដូចជាសោកសៅចម្លែក...

បើបានជាក្រដាសគំនូរមួយសន្លឹកនេះ នាំឲ្យខ្ញុំនឹកឃើញរឿងច្រើនដល់ម្ល៉ឹង ខ្ញុំក៏គ្មានហេតុផលអ្វីត្រូវទុកវាទៀតដែរ។ ត្រឹមតែប្រឈមមុខនឹងការពិតក្នុងរយៈពេលបិទខ្ទប់នេះ វាតឹងតែងណាស់ហើយ ខ្ញុំមិនត្រូវការអ្វីមួយមកក្រើនរំលឹកខ្ញុំពីរឿងមិនសប្បាយចិត្តពីអតីតកាលទៀតនោះទេ។

គិតរួចហើយ ខ្ញុំក៏ខ្ញីខ្ញុកក្រដាសនោះ រួចបោះវាចូលធុងសំរាម ហើយយកធុងនោះទៅចោលនៅធ្លាក្រោយផ្ទះ។ គ្រានោះ ខ្ញុំមិនបានដឹងទេថា ក្រដាសគំនូរមួយសន្លឹកនោះបានធ្លាក់ដល់ដីប៉ារបស់ខ្ញុំដោយចៃដន្យ ពេលដែលគាត់ប្រមូលសំរាមទៅចោល។ ពេលដែលខ្ញុំចេញមកយកទឹកនៅយប់បន្តិច ខ្ញុំបានឃើញប៉ាកំពុងកាន់ក្រដាសគំនូរនោះមើលតែម្នាក់ឯងនៅតុអង្គុយលេងក្រោយផ្ទះ។ ខ្ញុំអាចមើលដឹងថាគាត់សោកសៅយ៉ាងខ្លាំង ហើយខ្ញុំក៏យល់ច្បាស់ថា រឿងរ៉ាវរវាងខ្ញុំនិងប៉ាកន្លងមកនេះគឺមានតែធ្វើឲ្យម្នាក់ៗឈឺចាប់រៀងខ្លួន សូម្បីតែប្អូនប្រុសតែម្នាក់របស់ខ្ញុំ។ ឃើញប៉ាអង្គុយសញ្ជឹងគិតស្រងេះស្រងោចថ្ងៃនេះ ទើបធ្វើឲ្យខ្ញុំយល់ថា បញ្ហាដែលពួកយើងជួបប្រទះ និងដោះស្រាយមិនបានកន្លងមក គឺដោយសារតែពួកយើងមិនបានជួបគ្នា មិនបាននិយាយគ្នា មិនបានយោគយល់គ្នា រហូតដល់ថ្ងៃនេះ ជាថ្ងៃដែលយើងជាប់ក្នុងផ្ទះជាមួយគ្នា និងមិនអាចគេចវេះបញ្ហានេះបន្តទៀត ទើបទីបំផុត យើងមានតែត្រូវប្រឈមមុខនឹងភាពភ័យខ្លាចរបស់យើងម្នាក់ៗដោយខានមិនបាន។

ព្រឹកថ្មី ខ្ញុំបើកទ្វារចេញពីបន្ទប់ទាំងងងុយនៅឡើយ គិតថានឹងទៅរកទឹកមកផ្សើមកបន្តិច តែពេលដែលបើកទ្វារភ្លាម ខ្ញុំក៏ប្រទះនឹងប្អូនប្រុសរបស់ខ្ញុំកំពុងឈរញញឹមនៅមុខបន្ទប់ តាំងពីពេលណាក៏មិនដឹង។ ខ្ញុំមើលមុខមុខវាវិញ ដោយមិននិយាយអ្វី តែក្នុងចិត្តមានសំណួរជាច្រើន។ គិរីក៏ស្ទុះចូលមកទាញដៃខ្ញុំ ដើរតម្រង់ទៅធ្លាក្រោយផ្ទះ។

ពេលដែលទៅដល់ ខ្ញុំក៏បានឃើញប៉ារបស់ខ្ញុំឈរចាំនៅទីនោះ ក្រោមម្លប់ឈើត្រឈឹងត្រឈៃ។ ប៉ាក្នុងឈុតរ៉ូបពណ៌លឿងយ៉ាងស្រស់ស្អាត ឯសក់វែងត្រឹមស្មារបស់គាត់ ត្រូវបានតុបតែងយ៉ាងរៀបរយ។ ខ្ញុំមិនដឹងថា ប៉ា និងគិរីចង់ធ្វើអ្វីឡើយ ទើបបានជាពួកគេបង្ហាញអាការៈចម្លែកៗមកខ្ញុំដូច្នេះ តែភ្លាមនោះ ភ្នែករបស់ខ្ញុំស្រាប់តែប្រទះឃើញអាងទឹកធំល្មមមួយនៅជ្រុងម្ខាងនៃធ្លាក្រោយផ្ទះនេះ។ មិនតែប៉ុណ្ណោះ វាថែមទាំងមានថ្មតូចធំបន្តុបពីលើគ្នាខ្ពស់ល្មម ព្រមទាំងមានទឹកហូរចុះមកក្រោម លម្អដោយទឹកបាញ់ទៅលើបណ្តាលឲ្យសាចមកត្រូវខ្ញុំខ្លះៗ។ វាជា...

ទឹកជ្រោះសិប្បនិម្មិត...

ខ្ញុំសម្លឹងទៅទឹកជ្រោះនោះមិនដាក់ភ្នែក ឯភាពក្តុកក្តួលមួយចំនួនស្រាប់តែលេចឡើងក្នុងចិត្តរបស់ខ្ញុំ។

ប៉ាចំណាយពេលអស់មួយយប់ធ្វើវាដើម្បីខ្ញុំឬ?

ខ្ញុំគាំងស្មៀមរកអ្វីនិយាយលែងចេញទៅហើយ ទើបខ្ញុំបានត្រឹមតែឈានជើងយឺតៗ រួចដើរចូលទៅក្នុងអាងទឹកនោះ។ ខ្ញុំដាក់ខ្លួនអង្គុយចុះយឺតៗ រួចផ្អែកខ្នងទៅនឹងថ្មដែលមានទឹកហូរចុះមក។ ខ្លួនរបស់ខ្ញុំសើមបន្តិចម្តងៗរហូតជោកពេញតួខ្លួន។ ប៉ា និងគិរីឈរផ្ទឹងមើលខ្ញុំដោយញញឹមបន្តិច សោកសៅបន្តិច។ ខ្ញុំសម្រួលអារម្មណ៍ងើយមុខមើលទៅលើ និងដោះលែងចិត្តខឹងសម្បារ ឲ្យហូរទៅតាមទឹកឲ្យអស់។ គ្រានោះខ្ញុំក៏បានប្រទះឃើញក្បាលទុយោទឹក ដែលលេចលឹមៗនៅខាងលើ វាស្រាប់តែបានធ្វើឲ្យខ្ញុំអស់សំណើចបន្តិច។ ទឹកជ្រោះដែលប៉ាធ្វើនេះ តាមពិតជាទឹកទុយោដ៏ធម្មតាមួយសោះ តែហេតុអ្វីបានជាវាធ្វើឲ្យខ្ញុំរីករាយខ្លាំងម្ល៉េះ? រីករាយខ្លាំងជាងកាលបានទៅដល់ទឹកជ្រោះប៊ូស្រាទៅទៀត។ ភាពរីករាយដែលខ្ញុំមាននេះ វាបាននាំមកនូវភាពក្តុកក្តួលដែលខ្ញុំបានលាក់ទុកក្នុងចិត្តជាយូរ ទើបទឹកភ្នែករបស់ខ្ញុំបានហូរចុះមកប្រណាំងនឹងទឹកជ្រោះសិប្បនិម្មិតនេះដែរ។

ខ្ញុំអង្គុយបញ្ឈរក្បាលជង្គង់ ជ្រប់មុខយំកណ្តាលទឹកជ្រោះដែលហូរពីក្បាល ទុយោទឹកវិញៗ។

"ហ៊ឺៗ" សំឡេងយំរបស់ខ្ញុំ បានធ្វើឲ្យប៉ា និងប្អូនប្រុសរបស់ខ្ញុំប្រញាប់រត់ចូលមកអង្គុយសងខាងលួងលោមខ្ញុំ។ ប៉ាបានទាញខ្ញុំទៅឱបយ៉ាងណែន។

"ឲ្យប៉ាសុំទោសណាកូន" ប៉ានិយាយដោយសំឡេងខ្សឹកខ្សួល ឯប្អូនរបស់ខ្ញុំក៏ចូលមកឱបប៉ានិងខ្ញុំយ៉ាងណែនដូចគ្នា។

"នេះជាទឹកជ្រោះដ៏អាក្រក់បំផុតដែលខ្ញុំធ្លាប់ឃើញ" ខ្ញុំរអ៊ូបណ្តើរយំបណ្តើរ។

"គេបិទប្រទេសហើយ ប៉ាមានតែទឹកជ្រោះមួយនេះទេសម្រាប់កូន"

ពេលឮប៉ានិយាយបែបនេះ ពួកយើងក៏បន្លឺសំណើចឡើង តែអ្វីដែលកាន់តែគួរឲ្យអស់សំណើចនោះគឺមុខរបស់ប៉ា។

"ខូចម្សៅលាបមុខអស់ហើយ" ខ្ញុំនិយាយទាំងសើចផង យំផង រួចយកដៃទៅជូតមុខប៉ា។ ប៉ាគ្រវីក្បាលតិចៗរួចសើចតប។

"មិនអីទេ ឲ្យតែកូនមិនស្អប់ប៉ា ដែលមានប៉ាជាមនុស្សបែបនេះ"

ខ្ញុំឮហើយ ខ្ញុំក៏តបទៅគាត់វិញ។

"ខ្ញុំមិនដែលស្អប់ប៉ាដែលប៉ាជាមនុស្សប្លែកភេទទេ តែខ្ញុំខឹងដែលប៉ាមិនគោរពសន្យា... តែមិនអីទេ មើលចុះ! ប៉ាបាននាំខ្ញុំមកលេងទឹកជ្រោះហើយ ខ្ញុំក៏លែងខឹងនឹងប៉ាដែរ"

អ្វីដែលខ្ញុំចង់បានគឺ គ្រាន់តែជាភាពទទួលខុសត្រូវរបស់ប៉ាប៉ុណ្ណោះ ខ្ញុំមិនចង់ឲ្យភាពខុសឆ្គងមួយនេះ នឹងត្រូវបំភ្លេចចោលទៅតាមពេលវេលានោះទេ។

ព្រោះសន្យាឪពុក ពិតជាមានតម្លៃណាស់សម្រាប់កូន!

បញ្ហាដែលកើតមានអស់ជាច្រើនឆ្នាំ ប្រហែលជាត្រូវបញ្ចប់ក្នុងថ្ងៃនេះហើយ។

ក្នុងរយៈពេលដែលពិភពលោកកំពុងប្រយុទ្ធនឹងជំងឺដ៏កាចសាហាវនេះ មនុស្សគ្រប់គ្នាប្រហែលជាត្រូវប្រឈមមុខនឹងបញ្ហាជាច្រើន មិនថាផ្លូវកាយ ឬផ្លូវចិត្តជាពិសេស ដោយសារតែយើងមិនអាចគេចវេះបាន ទើបយើងប្រាកដជាមានអារម្មណ៍ថា ប្រៀបដូចជាកំពុងជាប់ទ្រឹងមួយកន្លែង ថែមទាំងត្រូវប្រឈមមុខនឹងរឿងមួយចំនួនដែលយើងតែងតែគេចវេះពីវា។ ប៉ុន្តែមិនចាំបាច់ទៅកន្លែងណាមួយ មិនចាំបាច់ទាល់តែប្រទេសបើកដំណើរការណ៍ធម្មតា ទើបយើងអាចស្វែងរកសុភមង្គលបាននោះទេ សុភមង្គលជាអ្វីដែលស្ថិតក្នុងចិត្តយើង មិនថានៅទីណា ឬជាមួយនរណា គ្រប់គ្នាសុទ្ធតែអាចរីករាយបាន។

ក្នុងគ្រាដ៏លំបាកនេះ អ្វីដែលយើងត្រូវរៀនគឺ រៀនទម្លាប់ និងរៀនទទួល។ អ្វីដែលខ្ញុំបានរៀនពីរយៈពេលនេះ គឺរៀនទម្លាប់នឹងការនៅមួយកន្លែង ដ្បិតខ្ញុំជាមនុស្សដែលចូលដើរហើរច្រើន និងមានអាជីពមួយដ៏មមាញឹក។ រៀនទទួលស្គាល់ថា នេះជាជីវិតថ្មីរបស់យើង ដោយមិនត្អូញត្អែរ និងមិនរអ៊ូរទាំ។ រៀនទម្លាប់នឹងរស់នៅជាមួយប៉ានិងប្អូនប្រុស ដែលពួកយើងធ្លាប់តែមិនចុះសម្រុងគ្នា រៀនទទួលស្គាល់ថាអ្វីជាបញ្ហារបស់ពួកយើងទាំងអស់គ្នា និងចេះអភ័យទោស រួចដើរបន្តទៅមុខទៀត។

ការផ្លាស់ប្តូរការរស់នៅក្នុងរដូវកាលកូវីដ១៩នេះ ប្រៀបដូចជាការរៀនស្គាល់ខ្លួនឯងម្តងទៀត។ យើងត្រូវផ្លាស់ប្តូរការញុំា ការដើរលេង ការទំនាក់ទំនងធ្វើការ និងរបៀបរស់នៅសឹងតែទាំងស្រុង។ ខ្ញុំមិនអាចគេចវេះនឹងការផ្លាស់ប្តូរទាំងនេះបានទេ

ដូចដែលខ្ញុំមិនអាចគេចវេះនឹងការប្រឈមមុខជាមួយប៉ារបស់ខ្ញុំដូចគ្នា។ រៀនទម្លាប់ រៀនទទួលស្គាល់ គឺជាអ្វីដែលចាំបាច់បំផុតសម្រាប់យើងក្នុងពេលនេះ។

ខ្ញុំបានរកឃើញខ្លួនឯងសាជាថ្មី...

ខ្ញុំពិតជាមិននឹកស្មានថា ការបិទខ្ទប់នេះ វាបានធ្វើឲ្យខ្ញុំបានស្វែងយល់ពីខ្លួនឯងសាជាថ្មីថា ខ្ញុំត្រូវចេះអភ័យទោស និងមិនត្រូវឃុំឃាំងខ្លួនឯងក្នុងអតីតកាលបន្តទៀត។ លើសពីនេះ ខ្ញុំក៏មានគ្រួសារដ៏កក់ក្តៅតូចមួយ មិនមែនមានតែម្នាក់ឯងឯកាដូចដែលខ្ញុំធ្លាប់យល់នោះដែរ។

គ្រាដែលទឹកត្រជាក់ប៉ះនឹងសាច់របស់ខ្ញុំ វាក៏បានធ្វើឲ្យខ្ញុំយល់ភ្លាមថា ទឹកជ្រោះប៊ូស្រាពិតជាទឹកជ្រោះដ៏ស្អាតបំផុត តែវាប្រហែលជាមិនមានអត្ថន័យជ្រាលជ្រៅដូចទឹកជ្រោះសិប្បនិម្មិតមួយនេះឡើយ ព្រោះទឹកជ្រោះដែលមានគ្រួសាររបស់ខ្ញុំគឺជាទឹកជ្រោះតែមួយដែលខ្ញុំចង់បាន។

**ចប់**

Asian Literature Project "YOMU" ©Japan Foundation